# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៤-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៧ ស្តីពី ការតែងតាំង លោក **លី បាត់ឡេង** ជា ឧកញ៉ា ១៥៦៥

២៤-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងព័ត៌មាន ចំនួន ២៨ រូប ១៥៦៦

២៤-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ៤២ រូប ១៥៦៧

២៤-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០០ ស្តីពី ការតែងតាំង លោក **គង់ សេង** ជា សមាជិកទី ២ នៃបញ្ញត្តិករទូរគមនាគមន៏កម្ពុជា សម្រាប់អាណត្តិទី ២ មានរយៈពេល ៣ ឆ្នាំ ១៥៦៩

២៧-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០១ ស្តីពី ការតែងតាំងឯកឧត្តម **ឌឹម សុខណ្ណារុំ** ជា ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ១៥៧០

២៧-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០២ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ដល់នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៩ រូប ១៥៧១

២៧-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៣ រូប ១៥៧២

២៧-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៤ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ជ័យ រិទ្ធី** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៥៧៣

២៧-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៥ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍ នាយនគរបាលថ្នាក់ ឧត្តមសេនីយ៍ ចំនួន ០២ រូប នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៥៧៤

២៧-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៦ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ១៥៧៥

២៧-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ចំនួន ០៤ រូប ១៩៧៦
២៧-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ សប្បុរសជន ចំនួន ០៤ រូប ១៩៧៧
២៧-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/១០៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ៤៧ រូប ១៩៧៨
២៧-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១០ ស្តីពី ការតែងតាំង លោកស្រី **ខ៊ូច គិមសួគ៌** ជា ឧកញ៉ា ១៩៨១
២៧-០១-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១១ ស្តីពី ការតែងតាំង ឯកឧត្តម **ហោ ដារិទ្ធ** ជា អនុរដ្ឋលេខាធិការ ក្រសួងផែនការ ១៩៨២

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៥-០២-២០១៣ -អនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្តីពី ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ ១៩៨៣
០៥-០២-២០១៣ -អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៤៩,៥៣៤០ ហិកតា នៅស្រុកលំផាត់ ខេត្តរតនគីរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែរ ប៊ីអិម យ៉ាញស្តុក សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៤៩ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ១៩៩២
០៥-០២-២០១៣ -អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៧១៩,៤១៥៦ ហិកតា នៅស្រុកលំផាត់ ខេត្តរតនគីរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែរ ប៊ីអិម យ៉ាញស្តុក សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១២ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ១៩៩៥
០៥-០២-២០១៣ -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៤,៩០៣៩ ហិកតា នៅស្រុកលំផាត់ ខេត្តរតនគីរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែរ ប៊ីអិម យ៉ាញស្តុក សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៥ គ្រួសារ និង រក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ១៩៩៩

០៦-០២-២០១៣ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំសរុប ២៧៧,៩០ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច និង កាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ " មណ្ឌលគិរី " និង ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៨០ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៦០២

២១-១១-២០១២ -អនុក្រឹត្យលេខ **២៦០១** ដល់អនុក្រឹត្យលេខ **២៦១៤** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦០៥

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦១៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៦១៩

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦២២

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦២៣

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦១៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦២៤

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦១៩ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៦២៥

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦២០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៦២៦

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦២១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦២៧

២១-១១-២០១២ -អនុក្រឹត្យលេខ ២៦២២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦២៨

២២-១១-២០១២ -អនុក្រឹត្យលេខ ២៦២៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៦៣៧

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និង កីឡា

២៨-១២-២០១២ -ប្រកាសរួមលេខ ១០១១ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ ក្រសួងអប់រំ យុវជន និង កីឡា ១៦៣៨

២៨-១២-២០១២ -ប្រកាសរួមលេខ ១០១២ សហវ.ប្រក ស្តីពី ការផ្តល់រង្វាន់លើកទឹកចិត្តជូន ក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១៦៤៥

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងផែនការ

២៨-១២-២០១២ -ប្រកាសរួមលេខ ១០១៥ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ ក្រសួងផែនការ ១៦៥០

២៨-១២-២០១២ -ប្រកាសរួមលេខ ១០១៦ សហវ.ប្រក ស្តីពី ការផ្តល់រង្វាន់លើកទឹកចិត្តជូន ក្រសួងផែនការ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១៦៥៤

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៩-០១-២០១៣ -ប្រកាសលេខ ០១២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន រ៉ុន ផេស្ទ័រ អ៊ីន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៦៥៨

២២-០១-២០១៣ -ប្រកាសលេខ ០៥៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីងខូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៦៦២

២២-០១-២០១៣ -ប្រកាសលេខ ០៥៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្ទេប ហ្វ៊ូតសកស៊ី អេស៊ា បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់, ស្រោមដៃ និង ស្រោមជើង ១៦៦៦

## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

២៥-០១-២០១៣ -សេចក្តីសម្រេចលេខ ០០២/១៣ កប.សសរ ស្តីពី ការបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ១៦៧០

## ៥-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០១២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំ ផេនគ្វីន អេនើជី** ១៦៧៣

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០១៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូ អេលីត ស៊ីឃ្យូរីធី ហ្វស** ១៦៧៥

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០២៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ស៊ី អេ អូ អ៊ិនវេសមេន** ១៦៧៧

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០២៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីឡា គ្រុប** ១៦៧៩

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិមអិលអាយ អ៊ិនដាស ទ្រៀល (ខេមបូឌា)** ១៦៨១

២២-៨-២០១១ -លិខិតបញ្ជាក់លេខ ៥០៣១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីលលីង មេធល អ៊ិនដាស ទ្រៀល ខមភេនី លីមីធីត** ១៦៨៣

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក លី បាក់ឡេង**

**ជា**

**ឧកញ៉ា**

ចរស.១៣០១.០៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការស្តីទីរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

### ចំពោះ

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងព័ត៌មាន ចំនួន២៨រូប
មានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិលើវិស័យព័ត៌មាន

### នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

ឯកឧត្តម **គន់ យ៉ាន**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- ឯកឧត្តម **ម៉ៅ អាយុទ្ធ** | ៦- ឯកឧត្តម **សម សារិន** |
| ២- ឯកឧត្តម **ថាច់ ផែន** | ៧- ឯកឧត្តម **ទី សារ៉ាន់** |
| ៣- ឯកឧត្តម **សេង សារុន** | ៨- ឯកឧត្តម **អ៊ុក គីមសេង** |
| ៤- ឯកឧត្តម **យូន វិចិត្រ** | ៩- ឯកឧត្តម **គាត់ លីហុក** |
| ៥- ឯកឧត្តម **គី ឡុង** | ១០- ឯកឧត្តម **សោម សារុន** |

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

ឯកឧត្តម **ផុស សុវណ្ណ**

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

| | |
|---|---|
| ១- ឯកឧត្តម **គីម គុណាវឌ្ឍន៍** | ៩- លោក **អ៊ុក កំពូល** |
| ២- ឯកឧត្តម **នុត ឈឿង** | ១០- លោក **សោម ប៊ូរ៉ា** |
| ៣- ឯកឧត្តម **ធន់ សារ៉ាត** | ១១- លោក **សុក សុពុទ្ធី** |
| ៤- លោក **ប៉ាង ណាត** | ១២- លោក **សាន ហួត** |
| ៥- លោក **ជ័យ វុឌ្ឍី** | ១៣- លោក **ម៉ម ម៉ាលី** |
| ៦- លោក **ជា សាវុធ** | ១៤- លោក **រស សៃ** |
| ៧- លោក **សរ មុយលី** | ១៥- លោក **យឹម ម៉ិនថន** |
| ៨- លោក **ធន់ សារឹម** | ១៦- លោក **ម៉ម ឈឿម** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤.១៣០១.០៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣

[illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៨៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ និងសប្បុរសជនចំនួន ៤២រូប ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍមូលដ្ឋានលើគ្រប់វិស័យ អោយមានការរីកចំរើនគួរជាទីមោទនៈ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងខេត្តកណ្តាល

**នូវ**

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **ម៉ែន សេស**
២-លោក **វង្ស វុំដាវុធ**
៣-លោក **ចាន់ ភិរម្យ**
៤-លោក **ហួត វឌ្ឍនា**
៥-លោក **ខួន មាស**
៦-លោក **នន់ សុផល**
៧-លោក **សុខ មនោរម្យ**

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **កែន សម្បត្តិ**
២-លោក **ហោ ច័ន្ទវ៉ាន្នី**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១-ឯកឧត្តម **សន នរិន្ទ**
២-លោក **សេង គង់**
៣-លោក **លី សារុន**
៤-លោកស្រី **ទីវ សុចិន្តា**
៥-លោកស្រី **ឆាន់ វីរិយា**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឃ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

| | |
|---|---|
| ១-លោក **ស៊ុន សុទ្ធី** | ២-លោក **ម៉ៅ សោភ័ណ** |
| ៣-លោក **មុំ គន្ធា** | ៤-លោក **ខៀវ ខេមរជាតិ** |
| ៥-លោក **ឡុង ជិនរិទ្ធ** | ៦-លោក **ណុប សំផុន** |
| ៧-លោក **ចាន់ សុភ័ក្រ** | ៨-លោក **អៀប ម៉ាន់ឌី** |
| ១១-លោក **អាន អ៊ា** | ៩-លោក **គិត ម៉ុណ្ណា** |
| ១០-លោក **តុង រិទ្ធី** | |

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

| | |
|---|---|
| ១-លោកឧត្តមសេនីយ៍ទោ **អ៊ឹម ពុធនិរា** | ២-លោក **ណេង បញ្ញា** |
| ៣-លោក **កុយ សាគន** | ៤-លោក **យូ អៀងអ៊ាង** |
| ៥-លោក **ហ៊ីង ជ័យរដ្ឋ** | ៦-លោក **សួន សុភាព** |
| ៧-លោក **ចៅ ស៊ីនៅ** | ៨-លោក **ឈាត ម៉ុនធឿន** |
| ៩-លោក **លឹម ដល្លា** | |

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

| | |
|---|---|
| ១-លោក **ឆើម សេរីវឌ្ឍន៍** | ២-លោក **ជា លន** |
| ៣-លោក **ណារ៉ា ចំរើន** | ៤-លោក **ឡេង ច័ន្ទសុភក្តិ** |
| ៥-លោក **ជូ សារ៉ាផៃ** | ៦-លោក **អ៊ុយ ម៉ុនណា** |
| ៧-លោក **ជា សុរក្សា** | ៨-លោក **ឈុន តារា** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរចា. ១៣០១. ១០០

លេខ: ៨៩ ច.ល

**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣១២/១៧៥ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **គង់ សេង** ជាសមាជិកទី ២ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា សម្រាប់អាណត្តិទី ២ មានរយៈពេល ៣ ឆ្នាំ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៣០១.១០១

លេខៈ ៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មករា ឆ្នាំ២០១៣
...រាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣

...ជ័យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ឌឹម សុវណ្ណារុំ** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៣០១.១០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ: ១០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៣
អគ្គលេខា[illegible]រាជរដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** ដំឡើងឋានន្តរសក្តិ ដល់ នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **ជា ស៊ីថន** អត្តលេខ ០០៨៥២២
២-ឧត្តមសេនីយ៍ត្រី **ប៊ុល សុគុណា** អត្តលេខ ០០១៧៤៨
៣-ឧត្តមសេនីយ៍ត្រី **ឈួន យូ** អត្តលេខ ០៣៧១៨៧
៤-ឧត្តមសេនីយ៍ត្រី **យ៉ង់ ម៉ៅ** អត្តលេខ ០៤៣៩៦៩

**ខ-ដំឡើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ស៊ីនហ្វា សែងចាន់** អត្តលេខ ០១១០៧២
២-វរសេនីយ៍ឯក **ដុម សុជាតា** អត្តលេខ ០១២២៦២
៣-វរសេនីយ៍ឯក **ជា នុសិទ្ធ** អត្តលេខ ០០៨៥៧៥
៤-វរសេនីយ៍ឯក **នៅ អំសាន្ត** អត្តលេខ ០៣១៧៧០
៥-វរសេនីយ៍ឯក **ខង បូរីវត្តិ** អត្តលេខ ០០៣៨៧៨

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៣រល.១៧០១.១០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៣*

លេខ: ១១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាងអគារផ្នែកឯកទេសសុខភាពផ្លូវចិត្តកុមារ និងវ័យជំទង់ និងជួយបណ្តុះបណ្តាលបច្ចេកទេស ដល់គ្រូពេទ្យក្នុងមន្ទីរពេទ្យជ័យជំនះ នៃមន្ទីរសុខាភិបាលខេត្តកណ្តាល កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
១- លោកវេជ្ជបណ្ឌិត គង់ ឈុនលី
២- លោក គឹម រតនា
ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា
- លោក ហេនរីគេ ហ៊ីហ្គាអេដូ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារស. ១៣០១.១០៤

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ:១០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៣
[illegible]លេខា[illegible]រាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រត្ដតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្ដមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ជ័យ រិទ្ធី** អត្តលេខ ០៦៤១ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

លេខៈ១០៧ ច.ល
**បានឃើញ និងយល់ព្រមចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**
**ស៊ឹម សុខា**

៣៣៣. ១៣០១. ១០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាល ជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន០២រូប នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១/ លោកឧត្តមសេនីយ៍ទោ **បូរីសាន ជីឡុម៉េស** អត្តលេខ ០២២៧

២/ លោកឧត្តមសេនីយ៍ទោ **គុល គីមលី** អត្តលេខ ០៣៦១ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសាផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៣.១៣០១.១០៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៣

លេខ: ១០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៣
អ្នកទទួលបន្ទុកខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- ឯកឧត្តមឧត្តមសេនីយ៍ទោ **ជា សារ៉េត** អត្តលេខ ៦១៦៩៧

២- ឯកឧត្តមឧត្តមសេនីយ៍ទោ **ហុក ធីន** អត្តលេខ ០៣០២ និងតែងតាំងជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១០៥ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

ចរក. ១៣០១.១០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ចំនួន ០៤រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស ជាគួបការ :

ឯកឧត្តម ម៉ុល លីម

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ស្លា ប្រយុទ្ធ
២- ឧត្តមសេនីយ៍ឯក ម៉ូលី ដា អត្តលេខ ០០៦៩
៣- ឧត្តមសេនីយ៍ឯក សុខ ធី អត្តលេខ ០៤០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារល.១៣០១.១០៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ: ១០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខាធិការ [illegible] រដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនចំនួន ០៤ រូប មានស្នាដៃល្អ ក្នុងការចូលរួមជួយ
កសាងនិងអភិវឌ្ឍន៍លើគ្រប់វិស័យ ក្នុងខេត្តព្រះសីហនុ កន្លងមក

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១- ឯកឧត្ដម ម៉ា ស៊ុនហ៊្វីត
២- ឧកញ៉ា ឈាង ម៉េង
៣- ឧកញ៉ា សូ ខួន
៤- ឧកញ៉ា តែ តាំងប៉ី

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣រក.១៣០១.១០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ ១០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០ ខែ ... ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជននិងមន្ត្រីរាជការចំនួន ៤៧ រូប មានស្នាដៃល្អ ក្នុងការចូលរួម
ជួយកសាងនិងអភិវឌ្ឍន៍លើគ្រប់វិស័យ ក្នុងខេត្តព្រះសីហនុ កន្លងមក

នូវ

**ក-គ្រឿងឥស្សរិយយស សម្តេច ព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីនាថ កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម ស្វ ជុងឡួរ
២- លោកជំទាវ ជាញ់ ឥល្លី
៣- លោកជំទាវ យិន រតនា
៤- លោកជំទាវ ស៊ា សំតា
៥- លោកជំទាវ ឈាំង ឈាទី
៦- លោកជំទាវ ឆា ជាទី
៧- ឧកញ៉ា អ៊ុត ធី

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តមបណ្ឌិត ទ៉ាន់ ឥល
២- ព្រះតេជគុណ ឱន់ សាម៉ន
៣- ឯកឧត្តម ឈាប ហេង
៤- លោក សោម សុធីរ
៥- លោក ឈេង ធិ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៦- ឧត្តមសេនីយ៍ទោ រស់ ឡៀត អត្តលេខ០០០៩៥៧

៧- ឧត្តមសេនីយ៍ត្រី ហេង ចន្ថា អត្តលេខ២០៦៨០៨

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១- ព្រះតេជគុណ ឌិន សាវ៉ាន់

២- ព្រះតេជគុណ មាស សុផល

៣- លោក សាវ៉ាត ច័ន្ទធីរៈ

៤- លោកស្រី កែម សម្បត្តិ

៥- លោក សុខ សេរី

៦- លោក សេង សុចន្ថា

៧- លោក ឌិត ធុន្នី

៨- វរសេនីយ៍ឯក ជា ធុន្នី អត្តលេខ០១៦៥៨៨

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម នេន ម៉ាល័យ

២- វរសេនីយ៍ឯក ព្រុំ សារ៉ុន អត្តលេខ០០០៩៥៥

៣- វរសេនីយ៍ឯក រស់ ឫទ្ធី អត្តលេខ០១០៤៨៦

៤- លោក ផាន់ ចួនឈាង

៥- លោក រស់ ស៊ាត

៦- លោកស្រី នួច ស៊ីថន

៧- លោក ម៉ាត សិត

៨- លោក ឈឹម ហុកយន

៩- វរសេនីយ៍ទោ សេន ពិជ័យ អត្តលេខ០១៧៩៣០

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១- ព្រះតេជគុណ អ៊ុំ ប៊ុនឈឿន

២- ព្រះតេជគុណ ឈឹម យុត

៣- ឯកឧត្តម ជា សុខឃាង

៤- លោក កង ឌីណាត

៥- លោក ម៉ែន សុផាត

៦- លោក អន តារៈ

៧- លោក ឌូ សាធុជ

៨- លោក គួច ជីហ្វៀង

៩- វរសេនីយ៍ឯក យិន ប៊ុនណាត អត្តលេខ០៤២៦

១០- វរសេនីយ៍ឯក ស៊ាង កុសល អត្តលេខ០៤២៧

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ និបទិន្ន

១- ព្រះតេជគុណ ប៊ុន ឈាង

២- លោក ពេញ សាយ

៣- លោក អ៊ឹង សារុំ

៤- លោក ស៊ូ មាន

៥- លោក សាន សុម៉ែន

៦- លោក អេង ឡេងស៊ាន់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរស. ១៣០១.១១០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ:១២៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣

អគ្គលេខាធិការស្តីទីរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/ ១១០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោកស្រី ង៉ូច គិមសួគី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នរល.១៣០១.១១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ១០២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ហោ ដារិទ្ធ** ជាអនុរដ្ឋលេខាធិការក្រសួងផែនការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៦.១៣០១.១១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ: ១០១ ច.ល
**ចំលងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឈុំ សុខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៩.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការដំឡើងសាលានាយទាហានថ្នាតពងទៅជាសាលានាយទាហានសកម្ម មានកម្រិតស្មើគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការដំឡើងឋានៈសាលាពេទ្យកងយោធពលខេមរភូមិន្ទទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១៣២ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះនិងដំឡើងឋានៈវិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការប្រែក្លាយសាលានាយទាហានចម្រុះទៅជាវិទ្យាស្ថានទ័ពជើងគោក
- បានឃើញអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការប្រែក្លាយសាលាជំនាញឯកទេសចម្រុះទៅជាវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀន/យោធាចារ្យ ដើម្បីរួមចំណែកអភិវឌ្ឍការបណ្តុះបណ្តាលធនធានមនុស្ស នៅតាមគ្រឹះស្ថានឧត្តមសិក្សាចំណុះក្រសួងការពារជាតិឱ្យមានគុណភាពខ្ពស់។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅដូចខាងក្រោម៖

- រៀបចំនីតិវិធីនិងយន្តការសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យនិងផ្តល់ឋានៈជាសាស្ត្រាចារ្យ
- កំណត់លក្ខខណ្ឌរបស់បេក្ខជនដែលអាចប្រឡងជ្រើសរើសជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រូបង្រៀន/យោធាចារ្យ នៅតាមគ្រឹះស្ថានឧត្តមសិក្សាចំណុះក្រសួងការពារជាតិដែលមានបំណងទទួលឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យក្នុងវិស័យការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ក្រុមប្រឹក្សាជាតិផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ

**មាត្រា ៤.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ សរសេរកាត់ថា **ក.ជ.ស.ក.ជ.** ដែលមានសមាសភាពមកពី៖

- តំណាងក្រសួងការពារជាតិ ១រូប ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- សាស្ត្រាចារ្យក្នុងវិស័យការពារជាតិ ៦រូប សមាជិក។

សមាសភាព**គ.ជ.ស.គ.ជ.** មានអាណត្តិ៣(បី)ឆ្នាំ ហើយអាចបន្តអាណត្តិរបស់ខ្លួនសាជាថ្មីទៀត។ សមាសភាពសាស្ត្រាចារ្យក្នុងវិស័យការពារជាតិជាសមាជិក**គ.ជ.ស.គ.ជ.** ត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ។

សមាសភាពជាក់ស្តែងនៃ**គ.ជ.ស.គ.ជ.** ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា ៥.-**

**គ.ជ.ស.គ.ជ.**មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អនុម័តនិងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់**គ.ជ.ស.គ.ជ.**
- កំណត់បែបបទស្តីពីការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើសមាសភាពគណៈមេប្រយោគសម្រាប់វាយតម្លៃសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ
- រៀបចំនិងអនុម័តគម្រោងថវិកាសម្រាប់ដំណើរការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- ទទួលនិងដោះស្រាយបណ្តឹងតវ៉ារបស់គណៈមេប្រយោគឬបេក្ខជន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា ៦.-**

សមាជិក**គ.ជ.ស.គ.ជ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៧.-**

**គ.ជ.ស.គ.ជ.**ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុង១(មួយ)ឆ្នាំ។

ការប្រព្រឹត្តទៅនៃអង្គប្រជុំនិងរបៀបរបបការងាររបស់**គ.ជ.ស.គ.ជ.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់**គ.ជ.ស.គ.ជ.**។

**មាត្រា ៨.-**

**គ.ជ.ស.គ.ជ.**មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ទីប្រឹក្សា ឬព្រឹទ្ធាចារ្យដែលមានបទពិសោធក្នុងការបណ្តុះបណ្តាលវិស័យការពារជាតិ ដើម្បីចូលរួមប្រជុំតាមការចាំបាច់។

**គ.ជ.ស.គ.ជ.**អាចទទួលទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអន្តរជាតិមួយចំនួនតាមការចាំបាច់។

**មាត្រា ៩.-**

**គ.ជ.ស.គ.ជ.**មាននាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិ ជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋាន**គ.ជ.ស.គ.ជ.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ។

**មាត្រា ១០.-**

**គ.ជ.ស.គ.ជ.**មានប្រភពធនធានមកពីថវិកាជាតិដែលជាកញ្ចប់ថវិការបស់ក្រសួងការពារជាតិ និងថវិកាបានមកពីការដាក់ពាក្យប្រឡងរបស់បេក្ខជនឬប្រភពផ្សេងៗទៀត។

**មាត្រា ១១.-**

ក.ជ.ស.ក.ជ.មានសិទ្ធិប្រើត្រាដោយឡែក ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៣
## ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ និងលក្ខខណ្ឌអប្បបរមាសម្រាប់ការប្រឡងជ្រើសរើស

**មាត្រា ១២.-**

ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ ត្រូវបានកំណត់ដូចខាងក្រោម៖

- សាស្ត្រាចារ្យជំនួយ
- សាស្ត្រាចារ្យរង និង
- សាស្ត្រាចារ្យ។

**មាត្រា ១៣.-**

បេក្ខជនដែលអាចប្រឡងជ្រើសរើសជាសាស្ត្រាចារ្យទៅតាមកម្រិតនីមួយៗដូចមានចែងក្នុងមាត្រា ១២ខាងលើនេះបាន ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក- សាស្ត្រាចារ្យជំនួយ

- មានសញ្ញាបត្រចាប់ពីកម្រិតក្រោយបរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងការពារជាតិនិង/ឬក្រសួងអប់រំ យុវជន និងកីឡាឬសញ្ញាបត្រសមមូលដែលមានតម្លៃស្មើដែលទទួលស្គាល់ដោយគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រនិងលិខិតបញ្ជាក់ការសិក្សា
- មានអត្ថបទស្រាវជ្រាវដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានដឹកនាំធ្វើនិក្ខេបបទឬបានធ្វើជាអ្នកជំនួយការដឹកនាំធ្វើនិក្ខេបបទ
- បាននិងកំពុងបង្រៀនមួយមុខវិជ្ជាដោយឯករាជ្យនិងស្រាវជ្រាវនៅគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិ
- បានចូលរួមស្រាវជ្រាវនិងបោះពុម្ពផ្សាយសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម។

ខ- សាស្ត្រាចារ្យរង

- បានបម្រើការងារជាសាស្ត្រាចារ្យជំនួយយ៉ាងតិច៤(បួន)ឆ្នាំ
- មានអត្ថបទស្រាវជ្រាវថ្មីដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសីទអន្តរជាតិដោយធ្វើបទឧទ្ទេសឬធ្វើបទបង្ហាញជាផ្ទាំងរូបភាព
- បានចូលរួមស្រាវជ្រាវនិងបោះពុម្ពផ្សាយសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន

- មិនធ្លាប់មានកំហុសវិជ្ជាជីវៈឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម។

គ- សាស្ត្រាចារ្យ

- បានបម្រើការងារជាសាស្ត្រាចារ្យរងយ៉ាងតិច៥(ប្រាំ)ឆ្នាំ
- មានសញ្ញាបត្របណ្ឌិត
- មានអត្ថបទស្រាវជ្រាវថ្មីដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសីទអន្តរជាតិដោយធ្វើបទឧទ្ទេសឬធ្វើបទបង្ហាញជាផ្ទាំងរូបភាព
- បានចូលរួមស្រាវជ្រាវនិងបោះពុម្ពផ្សាយសៀវភៅសិក្សាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិម។

**មាត្រា ១៤.-**

លក្ខខណ្ឌលម្អិតពាក់ព័ន្ធនឹងជំនាញនីមួយៗក្នុងវិស័យការពារជាតិ សម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យតាមឋានៈនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់**គ.ជ.ស.គ.ជ**.។

## ជំពូកទី៤
## នីតិវិធីនៃការជ្រើសរើស
### ផ្នែកទី១
### នីតិវិធីនៃការជ្រើសរើសគណៈមេប្រយោគ

**មាត្រា ១៥.-**

សាកលវិទ្យាធិការឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិ ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគមួយដែលរៀបចំឡើងដោយគណៈកម្មាធិការបច្ចេកទេសនៃគ្រឹះស្ថានរបស់ខ្លួន យោងតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ទៅ**គ.ជ.ស.គ.ជ**. ដើម្បីសុំការអនុម័តយល់ព្រម។ **គ.ជ.ស.គ.ជ**.ត្រូវផ្តល់ការយល់ព្រមឬបដិសេធលើសមាសភាពគណៈមេប្រយោគក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីបដិសេធ **គ.ជ.ស.គ.ជ**.ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធទៅសាកលវិទ្យាធិការឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិពាក់ព័ន្ធ ដើម្បីធ្វើការរៀបចំសមាសភាពជាថ្មីឡើងវិញ។ បន្ទាប់ពីទទួលបានការយល់ព្រមលើសមាសភាពគណៈមេប្រយោគ សាកលវិទ្យាធិការឬនាយកនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិពាក់ព័ន្ធ ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគនេះទៅរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីធ្វើការតែងតាំង។

**មាត្រា ១៦.-**

គណៈមេប្រយោគដែលទទួលបានការតែងតាំង មានឆន្ទានុសិទ្ធិក្នុងការវាយតម្លៃលើបេក្ខជនដើម្បីទទួលបានឋានៈសាស្ត្រាចារ្យណាមួយ។

**មាត្រា ១៧.-**

សមាសភាពគណៈមេប្រយោគសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យត្រូវមានដូចខាងក្រោម៖

ក- សាស្ត្រាចារ្យជំនួយ

សមាសភាពគណៈមេប្រយោគមានចំនួន៧(ប្រាំពីរ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងនិងមានអតីតភាពយូរជាងគេជាប្រធាន
- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យជំនួយជាសមាជិកដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យក្នុងឋានៈណាមួយមកពីជំនាញឯកទេសនៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

ខ- សាស្ត្រាចារ្យរង

សមាសភាពគណៈមេប្រយោគមានចំនួន៧(ប្រាំពីរ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានអតីតភាពយូរជាងគេជាប្រធាន
- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងជាសមាជិកដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យឬសាស្ត្រាចារ្យរងមកពីជំនាញឯកទេសនៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

គ- សាស្ត្រាចារ្យ

សមាសភាពគណៈមេប្រយោគមានចំនួន៥(ប្រាំ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានអតីតភាពយូរជាងគេជាប្រធាន
- សាស្ត្រាចារ្យចំនួន២(ពីរ)រូបជាសមាជិក
- សាស្ត្រាចារ្យដែលអញ្ជើញមកពីគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិដទៃទៀតចំនួន២(ពីរ)រូបជាសមាជិក។

## ផ្នែកទី២
## នីតិវិធីនៃការប្រឡងជ្រើសរើសសាស្ត្រាចារ្យនិងការផ្តល់ឋានៈ

**មាត្រា ១៨.-**

ចំនួនសាស្ត្រាចារ្យគ្រប់កម្រិតរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗក្នុងវិស័យការពារជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា ១៩.-**

បេក្ខជនដែលមានបំណងប្រឡងដើម្បីទទួលឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះត្រូវដាក់ពាក្យស្នើសុំទៅគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិដោយភ្ជាប់មកជាមួយនូវ៖

- ពាក្យស្នើសុំប្រឡងជ្រើសរើស
- ច្បាប់ចម្លងសញ្ញាបត្រវិជ្ជាជីវៈ
- ផែនការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់បេក្ខជន
- លិខិតថ្កោលទោស

- ឯកសារផ្សេងៗទៀតតាមការចាំបាច់។

គំរូពាក្យស្នើសុំសម្រាប់ការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់**គ.ជ.ស.គ.ជ.**។

**មាត្រា ២០.-**

បែបបទនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់**គ.ជ.ស.គ.ជ.**។

**មាត្រា ២១.-**

សាកលវិទ្យាធិការឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិ ត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគទៅ**គ.ជ.ស.គ.ជ.** ដើម្បីសុំការយល់ព្រម។ រាល់ការជំទាស់ណាមួយរបស់**គ.ជ.ស.គ.ជ.** ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់អំពីមូលហេតុនៃការជំទាស់។

ក្នុងករណីមានវិការៈខាងទម្រង់ណាមួយក្នុងនីតិវិធីនៃការប្រឡងជ្រើសរើសដែលអាចធ្វើនិយតកម្មបាន **គ.ជ.ស.គ.ជ.** ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយតម្រូវឱ្យគណៈមេប្រយោគកែតម្រូវឡើងវិញ។

បេក្ខជនដែលមិនយល់ព្រមនឹងលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ មានសិទ្ធិប្តឹងតវ៉ាទៅ**គ.ជ.ស.គ.ជ.** ដើម្បីស្នើសុំពិនិត្យឡើងវិញ។ ក្នុងការពិនិត្យលើបណ្តឹងតវ៉ានេះ **គ.ជ.ស.គ.ជ.**ត្រូវគោរពតាមអំណាចឆន្ទានុសិទ្ធិរបស់គណៈមេប្រយោគដែលមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះ។

នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ារបស់បេក្ខជន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់**គ.ជ.ស.គ.ជ.**។

**មាត្រា ២២.-**

បន្ទាប់ពីទទួលបានការយល់ព្រមពី**គ.ជ.ស.គ.ជ.** លើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ និងមិនមានការប្តឹងតវ៉ាណាមួយលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគសាកលវិទ្យាធិការឬនាយកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យការពារជាតិពាក់ព័ន្ធ ត្រូវបញ្ជូនលទ្ធផលប្រឡងរបស់បេក្ខជនជូនរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីរៀបចំស្នើតែងតាំង។

ឋានៈជាសាស្រ្តាចារ្យជំនួយ សាស្រ្តាចារ្យរងនិងសាស្រ្តាចារ្យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

## ជំពូកទី៥
## បន្ទុកការងាររបស់សាស្រ្តាចារ្យ

**មាត្រា ២៣.-**

បន្ទុកការងាររបស់សាស្រ្តាចារ្យតាមកម្រិតនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.-**

ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន នៅពេលដែលមិនទាន់មានសាស្រ្តាចារ្យជំនួយ សាស្រ្តាចារ្យរងនិងសាស្រ្តាចារ្យ រាជរដ្ឋាភិបាលត្រូវរៀបចំស្នើតែងតាំងផ្តល់ឋានៈជាសាស្រ្តាចារ្យជំនួយ សាស្រ្តាចារ្យរង និងសាស្រ្តាចារ្យមួយចំនួនតាមការចាំបាច់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...០៥...ខែ...កុម្ភៈ...ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......៤៩..........អនក្រ.បក ចុះថ្ងៃទី..០៥...ខែ...កុម្ភៈ....ឆ្នាំ២០១៣ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ

## សទ្ទានុក្រម

**១- វិស័យការពារជាតិ:** សំដៅដល់ដែនសមត្ថកិច្ចក្នុងការការពារបូរណភាពដែនដី និងអធិបតេយ្យរបស់ជាតិ។

**២- គ្រូបង្រៀន:** សំដៅដល់បុគ្គលដែលមិនមែនជាយោធាចារ្យ ហើយដែលបង្រៀនមុខវិជ្ជាទូទៅនៅតាមគ្រឹះស្ថានសិក្សានៃក្រសួងការពារជាតិ។

**៣- យោធាចារ្យ:** សំដៅដល់យោធិនដែលបង្រៀនជំនាញវិជ្ជាជីវៈយោធា ហើយដែលត្រូវបានទទួលការតែងតាំងដោយប្រកាសរបស់ក្រសួងការពារជាតិ។

**៤- សាស្ត្រាចារ្យ:** សំដៅដល់គ្រូបង្រៀន ឬយោធាចារ្យ ដែលបានទទួលឋានៈតាមអនុក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ។

---

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៩៤៩,៥៣៤០ ហិកតា នៅស្រុកលំផាត់ ខេត្តរតនគិរី ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែម ប៊ីអិម យ៉ាញស្តុក សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៤៩ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១៩/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ៩៤៩,៥៣៩០ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែរ ប៊ីអិម យ៉ញស្តុក សម្រាប់ធ្វើប្រទានកម្ម ទំហំ ៧៩៦,០២០៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៥៣,៥១៣១ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី ។

**មាត្រា៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ២៣៤ ក្បាលដី ជូនប្រជាពលរដ្ឋ ១៤៣ គ្រួសារ នៅភូមិសមុទ្រលើ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី ។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៧១៩,៤១៥៦ ហិកតា នៅស្រុកលំផាត់ ខេត្តរតនគិរី ចេញពីដី សម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន អេលែវ ប៊ីអិម យ៉ុញស្តុក សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១២ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ២៥៨គ្រឿង ជូនមន្ត្រីរាជការ នៃកំពង់ផែស្វយ័តភ្នំពេញ ចំនួន ២៥៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិ មាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១- | លោកស្រី | **ឃ្លោក ស៊ីណេត** | បុគ្គលិក |
| ២- | លោកស្រី | **ឆិត សុខឿន** | បំរើភ្ញៀវ |
| ៣- | លោកស្រី | **ម៉ិន ញ៉** | បំរើភ្ញៀវ |
| ៤- | លោកស្រី | **ឈាង ស៊ីយឿន** | បំរើភ្ញៀវ |
| ៥- | លោក | **ផាម គី** | បើកបររថយន្ត |
| ៦- | លោក | **ឆិត្យ ម៉ុនធី** | បើកបររថយន្ត |
| ៧- | លោក | **ណារ៉េ សុផល** | បើកបររថយន្ត |
| ៨- | លោក | **អ៊ិន សំអុល** | បើកបររថយន្ត |
| ៩- | លោក | **យ៉ែម ម៉ាប់** | ជាងភ្លើង |
| ១០- | លោក | **អ៊ឹម ចន្ថា** | បញ្ជាការរងសន្តិសុខ |
| ១១- | លោក | **ហ៊ីង សារុំ** | ប្រធានក្រុម ១ |
| ១២- | លោក | **ឡុង អេង** | សមាជិកក្រុម ២ |
| ១៣- | លោក | **ស សុវណ្ណ** | សមាជិកក្រុម ២ |

| | | | |
|---|---|---|---|
| ១៤- | លោក | ទូច ឆាយ៉ា | ប្រធានផ្នែក |
| ១៥- | លោក | ជាម សុផាន្នេរ | អនុប្រធានអង្គភាពក្តាប់រួម |
| ១៦- | លោកស្រី | ឯម សុគន្ធារី | ប្រធានផ្នែកគ្រឿងបន្លាស់ |
| ១៧- | លោកស្រី | ឯក ចំន្ទវណ្ណា | ប្រធានផ្នែកហិរញ្ញកិច្ច |
| ១៨- | លោកស្រី | សុខ សុវណ្ណធារី | បេឡា |
| ១៩- | លោកស្រី | អៀង ចន្នី | អនុប្រធានផ្នែកគណនេយ្យ |
| ២០- | លោក | ហេង តូ | អនុប្រធានផ្នែកហិរញ្ញកិច្ច |
| ២១- | លោក | ហាក់ សាន | អនុប្រធានផ្នែកឃ្លាំងសំភារៈ |
| ២២- | លោក | ទីម វណ្ណសុខន | បុគ្គលិក |
| ២៣- | លោក | មៀច យោធិន្ទ | ប្រធានផ្នែក ថែទាំទីលាន |
| ២៤- | លោក | សៅ វាសនា | បុគ្គលិក |
| ២៥- | លោក | ឈាង កុសល | បុគ្គលិក |
| ២៦- | លោក | ខាត់ ចន្ទូ | បុគ្គលិក |
| ២៧- | លោក | អ៊ុំ រដ្ឋា | បុគ្គលិក |
| ២៨- | លោក | ជួន សារិទ្ធិ | អនុប្រធានផ្នែកសាឡាងទី១ |
| ២៩- | លោក | ហៀក ផល | អនុប្រធានផ្នែកសាឡាងទី២ |
| ៣០- | លោក | រឿន ឈុនឡេង | អនុប្រធានផ្នែកសាឡាងបូមដី |
| ៣១- | លោក | ម៉ុម មុន្នីរត្ន | យន្តការី សាឡាងបូមដីទី ១ |
| ៣២- | លោក | លៀង សុវណ្ណា | បើកបររថយន្តបែន |
| ៣៣- | លោក | វង់ សុធា | បរិបាលកាណូត |
| ៣៤- | លោក | ប៉េង ណេង | បុគ្គលិកពោងទុយោ |
| ៣៥- | លោក | ពិន សុផល្លី | ប្រធានផ្នែក(យន្តការី ជាងភ្លើង) |
| ៣៦- | លោក | ឈាង សុគ្រី | យន្តការី សាឡាងបូមដីទី ២ |
| ៣៧- | លោក | ចាន់ ពៅ | បរិបាលកាណូត |
| ៣៨- | លោក | ផៃ ណុន | ប្រធានក្រុមសាឡាងទី២ |
| ៣៩- | លោក | ច្រឹក យឿន | បរិបាលកាណូត |
| ៤០- | លោក | ទឹម ធុល | អនុប្រធានក្រុមវាស់ស្ទង់ |
| ៤១- | លោក | អ៊ុក អៀង | បុគ្គលិក |
| ៤២- | លោក | ស្រ៊ុន ម៉ុនថន | បុគ្គលិក |
| ៤៣- | លោក | នៅ សុខជាប | ប្រធានផ្នែក |
| ៤៤- | លោក | ផាត់ វ៉ាន់នី | ប្រធានផ្នែកនាវាសណ្តោង |
| ៤៥- | លោក | ទេព ដារ៉ាវត្ត | ប្រធានក្រុម |
| ៤៦- | លោក | ម៉ិញ ណារ៉ាន់ | ប្រធានក្រុមអនុរក្ស |
| ៤៧- | លោកស្រី | វ៉ា សុផុន | បុគ្គលិក |
| ៤៨- | លោក | ម៉ូ ហ៊ុច | យន្តការីនាវាសណ្តោង |

| | | | |
|---|---|---|---|
| ៤៩- | លោក | ញឹម សេន | បើកបរកាណូតចម្លង |
| ៥០- | លោក | កៅ សុគុណ | អនុប្រធានអង្គភាពកណ្ណធារ |
| ៥១- | លោក | ចំន្ទ ចំណា | អនុប្រធានផ្នែកកណ្ណធារ |
| ៥២- | លោក | ច្រាក់ ស៊ីណារ៉ាត់ | កណ្ណធារ |
| ៥៣- | លោក | នូ វណ្ណៈ | កណ្ណធារ |
| ៥៤- | លោក | កៅ ម៉ុនឈឿ | កណ្ណធារ |
| ៥៥- | លោក | ខាន់ សុវណ្ណារ៉ា | កណ្ណធារ |
| ៥៦- | លោក | ឃួត មាន | កណ្ណធារ |
| ៥៧- | លោក | យូរ មុន្នីរដ្ឋា | កណ្ណធារ |
| ៥៨- | លោក | ម៉ិន ម៉ូលីចំន្ទ | កណ្ណធារ |
| ៥៩- | លោក | មាស សាផន | ប្រធានផ្នែក |
| ៦០- | លោក | តែ គៀនតាំង | ប្រធានផ្នែក |
| ៦១- | លោក | ចាន់ សុផុន | ប្រធានផ្នែក |
| ៦២- | លោក | ស៊ិន ប្រសើរ | ប្រធានក្រុម |
| ៦៣- | លោក | គង់ ខា | ប្រធានក្រុម |
| ៦៤- | លោក | អ៊ុន ឆូច | អនុប្រធានអង្គភាព |
| ៦៥- | លោក | ពៅ សារ៉ាវឌ្ឍ | ប្រធានផ្នែក |
| ៦៦- | លោកស្រី | ជា សុខា | អនុប្រធានផ្នែកស្ថិតិ |
| ៦៧- | លោកស្រី | ម៉េង គីមឃាង | ប្រធានក្រុមផែនការ |
| ៦៨- | លោក | រីម សុខរ័ត្ន | អនុប្រធានអង្គភាព |
| ៦៩- | លោកស្រី | នូ ចំន្ទលក្ខិណា | ប្រធានផ្នែក |
| ៧០- | លោកស្រី | អ៊ុក មនោឫទ្ធី | បុគ្គលិក |
| ៧១- | លោកស្រី | ផាន់ សុវណ្ណា | បុគ្គលិក |
| ៧២- | លោក | ស្វាយ ពឌ្ឍ | អនុប្រធានអង្គភាព |
| ៧៣- | លោក | សួង សុខា | ប្រធានផ្នែកទីលាន |
| ៧៤- | លោកស្រី | គីម គីរ៉ា | ប្រធានផ្នែក |
| ៧៥- | លោកស្រី | ឯក ចំន្ទណាទី | បុគ្គលិក |
| ៧៦- | លោកស្រី | ណាវ សារ៉ាន់ | បុគ្គលិក |
| ៧៧- | លោក | ឡឹក សុវណ្ណា | បុគ្គលិក |
| ៧៨- | លោក | ឃុត សារិទ្ធ | បុគ្គលិក |
| ៧៩- | លោកស្រី | ស៊ិន កល្យាណ | បុគ្គលិកកត់ត្រា |
| ៨០- | លោកស្រី | សម ស៊ីណាន | បុគ្គលិកកត់ត្រា |
| ៨១- | លោក | ឧត ចាន់វុត្ថា | បុគ្គលិកកត់ត្រា |
| ៨២- | លោក | ជូ កុសល | បុគ្គលិកកត់ត្រា |
| ៨៣- | លោក | អ៊ិន សុខផេង | អនុប្រធានផ្នែកទីលាន |
| ៨៤- | លោកស្រី | សឹង រះវិ | អនុប្រធានក្រុម |

| | | | |
|---|---|---|---|
| ៨៥- | លោកស្រី | ជ័យ ចាន់ថាវី | បុគ្គលិក |
| ៨៦- | លោក | សៅ សុវណ្ណ | បុគ្គលិក |
| ៨៧- | លោក | តាន់ លាងចាន់ | បើកបររថយន្ត |
| ៨៨- | លោក | ទីម សារិន | ប្រធានក្រុម |
| ៨៩- | លោក | តិន សុវណ្ណ | អនុប្រធានអង្គភាព |
| ៩០- | លោក | ក្មួយ សារ៉េត | ប្រធានផ្នែកគ្រឿងចក្រ |
| ៩១- | លោក | អ៊ុំ វណ្ណា | ប្រធានក្រុមរថស្ទូច |
| ៩២- | លោកស្រី | ឈាន គីមបុប្ផា | បុគ្គលិក |
| ៩៣- | លោកស្រី | សេក ផល្លា | បុគ្គលិក |
| ៩៤- | លោក | ឈឹម សុគន្ធ | បុគ្គលិក |
| ៩៥- | លោក | លុក គីមចា | ជាងម៉ាស៊ីនភ្លើង |
| ៩៦- | លោក | ស្រី គីមស្រេង | បើកបររថយន្ត |
| ៩៧- | លោក | ចាន់ សុខា | បើកបររថយន្ត |
| ៩៨- | លោក | ចាន់ ដា | បើកបររថយន្ត |
| ៩៩- | លោក | ឆាត រ៉េន | បើកបររថយន្ត |
| ១០០- | លោក | យឹម ស៊ីផាត | បើកបររថយន្ត |
| ១០១- | លោក | ដា អៃ | បើកបររថយន្ត |
| ១០២- | លោក | ឌុច សាឌុង | បើកបររថយន្ត |
| ១០៣- | លោក | ហេង សំណាង | បើកបររថស្ទូច |
| ១០៤- | លោក | ហ៊ូ សៀក | បើកបររថស្ទូច |
| ១០៥- | លោក | អ៊ុង កុមារបណ្ឌិត | បើកបររថស្ទូច |
| ១០៦- | លោក | ម៉ម ថន | បើកបររថស្ទូច |
| ១០៧- | លោក | ឡាំង ឆាង | បើកបររថស្ទូច |
| ១០៨- | លោក | ណាវ សុខគ្រឿន | បើកបររថស្ទូច |
| ១០៩- | លោក | លួន ចាន់ណាឌុង | បើកបររថស្ទូច |
| ១១០- | លោក | តែ ឡុង | បើកបររថស្ទូច |
| ១១១- | លោក | ញាណ ម៉ុនធឿន | បើកបររថចូក |
| ១១២- | លោក | ម៉ុន សាវឿន | បើកបររថចូក |
| ១១៣- | លោក | វង់ ធីម៉ូ | បើកបររថចូក |
| ១១៤- | លោក | សេង សុខេង | បើកបររថចូក |
| ១១៥- | លោក | ព្រុំ គា | មេការ |
| ១១៦- | លោក | យឹម សឿន | មេការ |
| ១១៧- | លោក | ស៊ុន សុផាន់ | ជំនួយមេការ |
| ១១៨- | លោក | យឹម សុភាព | ជំនួយមេការ |
| ១១៩- | លោក | សុក សាយឿន | ជំនួយមេការ |
| ១២០- | លោក | នុត រ៉ូ | ប្រធានក្រុមកម្មករ |

| | | | |
|---|---|---|---|
| ១២១- | លោក | រស់ សេង | មេការ |
| ១២២- | លោក | ហេង សាវុធ | ជំនួយមេការ |
| ១២៣- | លោក | សៅ ផន | ជំនួយមេការ |
| ១២៤- | លោក | ចក់ មាន | មេការ |
| ១២៥- | លោក | សួន ឈុយ | មេការ |
| ១២៦- | លោក | ទឹម បូរ៉ា | មេការ |
| ១២៧- | លោក | មុត ហ៊ង | ជំនួយមេការ |
| ១២៨- | លោក | មាស សំអាង | ជំនួយមេការ |
| ១២៩- | លោកស្រី | ប៉ាល់ សុខុម | បុគ្គលិក |
| ១៣០- | លោក | អ៊ា សារឿន | ជំនួយមេការ |
| ១៣១- | លោក | សាំង សារឿន | កម្មករ |
| ១៣២- | លោក | សំ សេងឈាង | អនុប្រធានអង្គភាព |
| ១៣៣- | លោកស្រី | ហ៊ីង ចំនួមុនី | អនុប្រធានអង្គភាព |
| ១៣៤- | លោក | ឈួន ម៉ូលី | អនុប្រធានផ្នែក |
| ១៣៥- | លោក | ចាន់ សុខា | ប្រធានក្រុម |
| ១៣៦- | លោក | ម៉ិញ វណ្ណៈ | ផ្សារគោន |
| ១៣៧- | លោក | សួស មុនី | ជាងម៉ាស៊ីន |
| ១៣៨- | លោក | ម៉ុំម ពលរិទ្ធិ | ជាងភ្លើង |
| ១៣៩- | លោក | ឡុង ឈុននី | អនុប្រធានអង្គភាព |
| ១៤០- | លោក | ថៃ សុថារី | អនុប្រធានអង្គភាព |
| ១៤១- | លោក | អ៊ុង សុគ័ន្ធត្រា | អនុប្រធានអង្គភាព |
| ១៤២- | លោក | ម៉ន តារៈ | អនុប្រធានអង្គភាព |
| ១៤៣- | លោក | សឿ ម៉ាច | អនុប្រធានអង្គភាព |
| ១៤៤- | លោក | ឡុង សារួន | ប្រធានក្រុម |
| ១៤៥- | លោក | ឃុន វុទ្ធី | ប្រធានផ្នែក |
| ១៤៦- | លោក | ដឹក យិត | ជាងម៉ាស៊ីន |
| ១៤៧- | លោក | កេត សុវណ្ណា | ប្រធានផ្នែកចក្តាឡីស័ក |

ខ-មេដាយប្រាក់ការងារ

| | | | |
|---|---|---|---|
| ១- | លោក | គង់ សាខន | សន្តិសុខ |
| ២- | លោក | ឈុំ មុន្នី | សន្តិសុខ |
| ៣- | លោក | មាស ខេមរ៉ា | សន្តិសុខ |
| ៤- | លោក | ផន សុភាព | សន្តិសុខ |
| ៥- | លោក | ដួង រុំ | សន្តិសុខ |
| ៦- | លោក | ឃីម បូរិន | សន្តិសុខ |
| ៧- | លោក | ឈីម លីម | សន្តិសុខ |
| ៨- | លោក | អួន តីរុណ | សន្តិសុខ |

| | | | |
|---|---|---|---|
| ៩- | លោក | ហេង សុខន | សន្តិសុខ |
| ១០- | លោក | គីម ប៊ុណារ៉ាត | សន្តិសុខ |
| ១១- | លោក | ឃុត នៅ | អនុប្រធានក្រុម |
| ១២- | លោក | ស៊ុន ផាក់ | បុគ្គលិក |
| ១៣- | លោកស្រី | ឡាយ ម៉ៃឡេង | បុគ្គលិក |
| ១៤- | លោក | ថា សូនី | បុគ្គលិក |
| ១៥- | លោក | គីម ស៊ីយុត | បុគ្គលិកថែទាំទីលាន |
| ១៦- | លោក | អ៊ុន ហ៊ួងគង់ | បើកបររថយន្តបែន |
| ១៧- | លោក | កែវ ឡា | ពោងទុយោ |
| ១៨- | លោក | អ៊ុក តារះ | អ្នកដឹក + ពោងទុយោ |
| ១៩- | លោក | ម៉ិច ម៉ុន្នី | បុគ្គលិកអង្គភាពវាស់ស្ទង់ |
| ២០- | លោក | ឈួន សុឃា | ប្រធានក្រុមកាណូតចម្លង |
| ២១- | លោក | អួរ ឈួន | អនុរក្ស |
| ២២- | លោក | ចាន់ សាមឿន | បើកបរនាវាសណ្តោង |
| ២៣- | លោក | តុប ឆាន | យន្តការីនាវាសណ្តោង |
| ២៤- | លោក | សឿង ចាន់តារា | យន្តការីនាវាសណ្តោង |
| ២៥- | លោក | មាន ប៊ុណ្ណា | យន្តការីនាវាសណ្តោង |
| ២៦- | លោក | ចន្ទ មករា | បុគ្គលិក |
| ២៧- | លោក | ខួន ពៅ | អនុប្រធានផ្នែក |
| ២៨- | លោក | គង់ សេរីវឌ្ឍនា | អនុប្រធានផ្នែក |
| ២៩- | លោក | ជូ គីមសាន | បុគ្គលិក |
| ៣០- | លោក | ពេជ្រ ចាន់ឌី | បុគ្គលិកកត់ត្រា |
| ៣១- | លោក | សុច ប៊ុនធឿន | បុគ្គលិកកត់ត្រា |
| ៣២- | លោកស្រី | ម៉ុត ប៉ុណ្ណរិកា | បុគ្គលិកកត់ត្រា |
| ៣៣- | លោក | អ៊ុច រដ្ឋ | បុគ្គលិក |
| ៣៤- | លោកស្រី | ឆា កណ្ណជា | បុគ្គលិក |
| ៣៥- | លោកស្រី | ឌុយ វណ្ណធារី | បុគ្គលិក |
| ៣៦- | លោក | ឆន់ សាម៉ុន | បុគ្គលិក |
| ៣៧- | លោក | មៀច ធីរ័ត្ន | បុគ្គលិក |
| ៣៨- | លោកស្រី | នឹង ម៉ារីនី | បុគ្គលិក |
| ៣៩- | លោកស្រី | ហេង ស៊ីណា | បុគ្គលិក |
| ៤០- | លោកស្រី | គង វិច្ឆរ៉ា | បុគ្គលិក |
| ៤១- | លោក | សំរិទ្ធ នី | បើកបររថយន្ត |
| ៤២- | លោក | ឡុង ផាន | បើកបររថយន្ត |
| ៤៣- | លោក | អ៊ុំ ចាន់ថន | បើកបររថយន្ត |
| ៤៤- | លោក | ឡិ ផល្លា | បើកបររថយន្ត |

| | | | |
|---|---|---|---|
| ៤៥- | លោក | កែវ ចាន់ចាសនា | បើកបររថយន្ត |
| ៤៦- | លោក | ញ៉ាញ់ គីម | បើកបររថយន្ត |
| ៤៧- | លោក | ខាត់ វណ្ណាត | បើកបររថយន្ត |
| ៤៨- | លោក | សុខ ម៉ៅ | បើកបររថយន្ត |
| ៤៩- | លោក | ថោង ថន | បើកបររថយន្ត |
| ៥០- | លោក | លុយ ឈិន | បើកបររថយន្ត |
| ៥១- | លោក | រស់ មុនវណ្ណា | បើកបររថយន្ត |
| ៥២- | លោក | ឌី ចន្ធី | បើកបររថស្ទូច |
| ៥៣- | លោក | ខិន សុផ្លានា | បើកបររថស្ទូច |
| ៥៤- | លោក | ឈឹម សុវណ្ណរិទ្ធ | បើកបររថស្ទូច |
| ៥៥- | លោក | ហ៊ិន ស៊ីណាត | បើកបររថស្ទូច |
| ៥៦- | លោក | ជ ថៃ | បើកបររថស្ទូច |
| ៥៧- | លោក | នៅ សារ៉េត | បើកបររថស្ទូច |
| ៥៨- | លោក | ហែម មុន្និន | បើកបររថស្ទូច |
| ៥៩- | លោក | ម៉ុន សុធារ៉ា | បើកបររថស្ទូច |
| ៦០- | លោក | អ៊ុក សារ៉េន | បើកបររថស្ទូច |
| ៦១- | លោក | ឡឿក ម៉ុន | បើកបររថស្ទូច |
| ៦២- | លោក | ពៅ សាវី | បើកបររថស្ទូច |
| ៦៣- | លោក | ឈុន តារៈ | បើកបររថចូក |
| ៦៤- | លោក | កែវ ម៉ូវ | បើកបររថចូក |
| ៦៥- | លោក | គីម សុវណ្ណារី | បើកបររថចូក |
| ៦៦- | លោក | វៀល សុខហេង | បើកបររថចូក |
| ៦៧- | លោក | កែវ គាក់ | បើកបររថចូក |
| ៦៨- | លោក | កែ សេង | បើកបររថចូក |
| ៦៩- | លោក | នៅ មិនា | បើកបររថចូក |
| ៧០- | លោក | ឯម វណ្ណី | បើកបររថចូក |
| ៧១- | លោក | អ៊ុន ហ៊ត | កម្មករ |
| ៧២- | លោក | ហ៊ាង រិទ្ធី | បើកបររថចូក |
| ៧៣- | លោក | ពេជ្រ សុផល | បើកបររថចូក |
| ៧៤- | លោកស្រី | អ៊ុក ដានី | បុគ្គលិក |
| ៧៥- | លោក | កៀង តាវី | កម្មករ |
| ៧៦- | លោក | សំ ចិន្តា | កម្មករ |
| ៧៧- | លោក | ស្រេង ខន | ជំនួយមេការ |
| ៧៨- | លោក | មាស ឥន | បុគ្គលិក |
| ៧៩- | លោក | សាយ សំបូរ | បុគ្គលិក |

| | | | |
|---|---|---|---|
| ៨០- | លោក | គង់ ម៉ៅ | បុគ្គលិក |
| ៨១- | លោក | ចែម ម៉ុន | បុគ្គលិក |
| ៨២- | លោក | ម៉ិល ថាច | បុគ្គលិក |
| ៨៣- | លោក | ឃាន ណារ៉ា | កម្មករ |
| ៨៤- | លោកស្រី | តន់ ចន្ធី | បុគ្គលិក |
| ៨៥- | លោក | ឃុន សំអឿន | កម្មករ |
| ៨៦- | លោក | នី សំអុល | កម្មករ |
| ៨៧- | លោក | ឡឹក សុខា | ជំនួយមេការ |
| ៨៨- | លោក | ភង លាង | កម្មករ |
| ៨៩- | លោក | ស ប៊ុនលី | កម្មករ |
| ៩០- | លោក | រស់ វណ្ណធី | ជំនួយមេការ |
| ៩១- | លោក | ប៊ិន ទ្រី | កម្មករ |
| ៩២- | លោក | ឡូច ឌី | កម្មករ |
| ៩៣- | លោក | កែវ សិទ្ធារ៉ា | កម្មករ |
| ៩៤- | លោក | ហៀង សុវណ្ណរតន៍ | ប្រធានក្រុម |
| ៩៥- | លោក | ទេព និមិត្ត | បុគ្គលិក |
| ៩៦- | លោក | ឡូច យូរ៉ាន់ | បុគ្គលិក |
| ៩៧- | លោក | ហ៊ឹង សុខា | អនុប្រធានអង្គភាព |
| ៩៨- | លោក | ហ៊ី សុង | ប្រធានផ្នែក |
| ៩៩- | លោក | ពៅ សារ៉ាវុធ | បុគ្គលិក |
| ១០០- | លោក | ពាង សុផ្លា | អ្នកបើករថយន្ត |
| ១០១- | លោក | ជ ត្រុង | បុគ្គលិក |
| ១០២- | លោក | មាស គីរីផល | បុគ្គលិក |
| ១០៣- | លោកស្រី | ម៉ិច សាវី | អនាម័យ |
| ១០៤- | លោក | ឡូន ចន្ទូ | អនាម័យ |

គ-មេជាងសំណង់ការងារ

| | | | |
|---|---|---|---|
| ១- | លោក | ម៉ៅ រដ្ឋា | បើកបររថយន្ត |
| ២- | លោក | យូ ចំនួនតារា | បុគ្គលិក |

៣- លោក  គីម សៀង  បុគ្គលិក

៤- លោក  គឿកជ្រុន ពុទ្ធីរ័ត្ន  កណ្ណធារ

៥- លោក  ស៊ុយ បញ្ញាបុត្រ  កណ្ណធារ

៦- លោក  តួច សៅលី  បើកបររថយន្ត

៧- លោក  កែន សាម៉ន  បុគ្គលិក

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួលៈ**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤១៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ចំនួន ០២គ្រឿង ជូនអ្នកបច្ចេកទេសចិន ដែលមានស្នាដៃល្អ ក្នុងការចូលរួមសាងសង់ផ្លូវជាតិលេខ៨ ពីស្ពានព្រែកតាមាក់ ដល់អន្លង់ជ្រៃ ព្រំដែនកម្ពុជា-វៀតណាម ប្រវែង ១០៩ គ.ម សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

១-Mr. CAO XUTIAN Deputy General Manager of Shanghai Construction Group Co.,Ltd

២-Mr.WU WEIRONG Project Manager of NR No 8 of Shanghai Construction Group Co.,Ltd

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០១១ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម

## ស្តីពី

## ការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាល នៃក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្រប តាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦** :

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជា ច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧** :

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបាន មុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការ ចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សិទ្ធី**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១០១១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | ការចេញអាជ្ញាប័ណ្ណ បើក | | | |
| | - ទារកដ្ឋាននិង/ ឬ មត្តេយ្យសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 400,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - ទារកដ្ឋាននិង/ ឬ មត្តេយ្យសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 1,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - ទារកដ្ឋាននិង/ឬមត្តេយ្យសិក្សាឯកជន(កម្មវិធីសិក្សាជាតិ) នៅខេត្ត | 200,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - ទារកដ្ឋាននិង/ឬមត្តេយ្យសិក្សាឯកជន(កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 400,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានបឋមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 2,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានបឋមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 4,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានបឋមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅខេត្ត | 1,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានបឋមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 2,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - បើកគ្រឹះស្ថានមត្តេយ្យសិក្សាដល់បឋមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 2,500,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់បឋមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 5,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់បឋមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅខេត្ត | 2,000,000 | 35ថ្ងៃ | 5ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់បឋមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 4,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាបឋមភូមិឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 2,500,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាបឋមភូមិឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 5,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 3,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 6,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាបឋមភូមិឯកជន (កម្មវិធីសិក្សាជាតិ) នៅខេត្ត | 1,500,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាបឋមភូមិឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 3,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាជាតិ) នៅខេត្ត | 2,500,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 5,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 3,500,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 7,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅខេត្ត | 3,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមធ្យមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 6,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានី | 4,500,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់មធ្យមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានី | 9,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាជាតិ) នៅខេត្ត | 3,000,000 | 35ថ្ងៃ | 5ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - គ្រឹះស្ថានមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅខេត្ត | 6,000,000 | 35ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានឧត្តមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) | 12,000,000 | 60ថ្ងៃ | 5ឆ្នាំ |
| | - គ្រឹះស្ថានឧត្តមសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) | 20,000,000 | 60ថ្ងៃ | 5ឆ្នាំ |
| | - សាខាគ្រឹះស្ថានឧត្តមសិក្សាឯកជន | 8,000,000 | 60ថ្ងៃ | 5ឆ្នាំ |
| | - ជំនាញ ឬកម្រិតបណ្តុះបណ្តាលថ្មីនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន | 8,000,000 | 60ថ្ងៃ | 5ឆ្នាំ |
| | **តម្លៃសេវាលើមុខងារដែលធ្វើប្រតិភូកម្មជូនការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក គោលដៅ** | | | |
| 2 | ការចេញអាជ្ញាប័ណ្ណ បើក | | | |
| | - សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) | 200,000 | 20ថ្ងៃ | 5ឆ្នាំ |
| | - សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីសិក្សាអន្តរជាតិ) | 400,000 | 20ថ្ងៃ | 5ឆ្នាំ |
| | - ថ្នាក់បណ្តុះបណ្តាលជំនាញ និងភាសាបរទេសវគ្គខ្លីៗតិចជាង 1ឆ្នាំ | 200,000 | 20ថ្ងៃ | 5ឆ្នាំ |
| 3 | ការចេញអាជ្ញាប័ណ្ណបង្កើតក្លឹបហាត់ប្រាណ | 200,000 | 20ថ្ងៃ | 5ឆ្នាំ |

**សេចក្តីបញ្ជាក់:**

- រាល់ការស្នើសុំបន្តសុពលភាពអាជ្ញាប័ណ្ណដែលមានក្នុងតារាងឧបសម្ព័ន្ធនេះ ក្រសួង/មន្ទីរអប់រំ យុវជន និងកីឡា កំណត់យកតម្លៃ ៥០% នៃតម្លៃសេវាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនេះ។ រយៈពេលផ្តល់សេវា និងសុពលភាពបន្ត មានរយៈពេលស្មើនឹងការស្នើសុំបើក។
- សុពលភាពបន្តជំនាញ ឬកម្រិតបណ្តុះបណ្តាលថ្មីនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន ឬសាខាគ្រឹះស្ថានឧត្តមសិក្សាឯកជនណា ត្រូវកំណត់តាមសុពលភាពរបស់គ្រឹះស្ថានឧត្តមសិក្សាឯកជន ឬសាខាគ្រឹះស្ថានឧត្តមសិក្សាឯកជននោះ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០១២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម

## ស្តីពី

## ការផ្តល់ទ្រូវលើកទឹកចិត្តជូន

## ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១០១១ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១ :**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២ :**

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ ៣ :**

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០១១ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងអប់រំ យុវជន និងកីឡា និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៤ :**

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងអប់រំ យុវជន និងកីឡា ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

- បង់ចូលថវិកាជាតិ ចំនួន ៥០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃចំណូលដែលប្រមូលបាន

**ប្រការ ៥ :**

រដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងអប់រំ យុវជន និងកីឡាដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៧** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម_សិទ្ធី**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៨ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០១៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម

# ស្តីពី

# ការផ្តល់សេវាសាធារណៈរបស់ក្រសួងផែនការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងផែនការ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងផែនការ អនុវត្តការប្រមូលចំណូលពីការចេញសញ្ញាបត្រដល់សិស្ស និស្សិតនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ ស្ថិតិ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

តម្លៃសេវានេះ ត្រូវបានកំណត់ចំនួន ២០.០០០ រៀល ក្នុងការចេញសញ្ញាបត្រមួយច្បាប់។

**ប្រការ ២** :

ក្រសួងផែនការ ត្រូវបិទផ្សាយជាសាធារណៈនូវប្រកាសរួម និងនីតិវិធីសម្រាប់ការស្នើសុំសញ្ញាបត្ររបស់សិស្ស និស្សិតនៅនឹងបញ្ជរនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ ស្ថិតិ ក្រសួងផែនការ។

ក្រសួងផែនការត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

ក្រសួងផែនការ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤ :**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការចេញសញ្ញាបត្រ របស់ក្រសួងផែនការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។ ក្រសួងផែនការ ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥ :**

រាល់ការប្រមូលចំណូលពីការចេញសញ្ញាបត្រដល់សិស្ស និស្សិតខាងលើ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦ :**

ក្រសួងផែនការ ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧ :**

ក្រសួងផែនការ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨ :**

តម្លៃសេវាសម្រាប់ការចេញសញ្ញាបត្រដល់សិស្ស និស្សិត ដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»

- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០១៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣

# ប្រកាសរួម
# ស្តីពី
# ការផ្តល់ទឹកប្រាក់លើកទឹកចិត្តជូន ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសអន្តរក្រសួងលេខ ១០១៥ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងផែនការ

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

អនុញ្ញាតឱ្យក្រសួងផែនការ កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១០១៥ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងផែនការ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនក្រសួងផែនការ សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះរួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងផែនការ និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

- បង់ចូលថវិកាជាតិ ចំនួន ១០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងផែនការ ចំនួន ៨៩% នៃចំណូលដែលប្រមូលបាន។
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន

**ប្រការ ៤** :

ក្រសួងផែនការ ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ក្រសួងផែនការ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការ នៃចំណូល និងចំណាយដទៃទៀតរបស់ក្រសួងផែនការដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយ លើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបាន បុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវ អនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖ ក្រសួង ផែនការ ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែន សារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពី ការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែក ប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិ ត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទាន ដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៥** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៤ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងផែនការ ត្រូវអនុលោមតាមការសម្រេចរបស់ រដ្ឋមន្ត្រីក្រសួងផែនការ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការ សម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែក តាមគុណសម្បត្តិការងារ។

**ប្រការ ៦** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៧ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ០១៤ ឧសក-សរ/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ០៤២ /១២ ត.ត.ស.ព ចុះថ្ងៃទី២៨.០២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន រ៉ុន ឆេស្ទ័រ អ៊ីន ចុះថ្ងៃទី១២.១២.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន រ៉ុន ឆេស្ទ័រ អ៊ីន (RONCHESTER INC.) តំណាងដោយលោក SHINICHI KASUGA សញ្ជាតិជប៉ុន អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខTK7263089 ចុះថ្ងៃទី២៦. ០៦.២០១២ មានអាសយដ្ឋានបច្ចុប្បន្ន: 7-5 Kano Sakaemachi-Dori, Gifu City, Gifu Prefecture, Japan. ជាម្ចាស់រោងចក្រ ប្រការបង្កើតរោងចក្រលើមុខសញ្ញាដូចខាង ក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ . ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

